# របាយការណ៍ប្រចាំខែសីហា ឆ្នាំ២០១៨ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តតាកែវ

## I. សេចក្តីផ្តើម

ចំនួនប្រជាពលរដ្ឋសរុប ៖ ក្នុងខេត្តតាកែវ មានប្រជាពលរដ្ឋសរុបចំនួន ៩២១.៨៧៦នាក់ ស្ត្រី ៤៧៦.៧៦០នាក់ ខេត្តតាកែវ មានផ្ទៃដីសរុបចំនួន ៣,៥៦២,៧០គីឡូម៉ែត្រការ៉េ ចែកជា ៖

- ផ្ទៃដីស្រូវប្រាំងសរុប ចំនួន ៨០,៥៨៦.៤ ហិចតា
- ផ្ទៃដីស្រូវវស្សាសរុប ចំនួន ១៦២,៧៨៩.៥ ហិចតា
- ផ្ទៃដីស្រូវបង្កើនរដូវសរុប ចំនួន ៤០,១១៣.៣៩ ហិចតា
- ផ្ទៃដីស្រូវចំការសរុប ចំនួន ២,៩៣១.២០ ហិចតា
- ផ្ទៃដីដំណាំរួមផ្សំសរុប ចំនួន ៤,៦៦៩ ហិចតា។

## II. ស្ថានភាពរបស់មន្ទីរ

1. ការងាររដ្ឋបាល និងបុគ្គលិក
   - មានមន្ត្រីរាជការសរុប ចំនួន ៩២ នាក់ ស្រី ១៩ នាក់
   - មានថ្នាក់ដឹកនាំមន្ទីរ ចំនួន ០៥ នាក់ ស្រី ០០ នាក់
   - មានមន្ត្រីថ្នាក់ខេត្ត ចំនួន ៦៧ នាក់ ស្រី ១៤ នាក់
   - មានមន្ត្រីថ្នាក់ស្រុក ចំនួន ២៦ នាក់ ស្រី ០៤ នាក់។
2. ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ
   - ការចំណាយថវិកា ជំពូក (៦០) ស្មើនិង ១០% ផែនការ
   - ការចំណាយថវិកា ជំពូក (៦១) ស្មើនិង ១០% ផែនការ
   - ការចំណាយថវិកា ជំពូក (៦៤) ស្មើនិង ១០% ផែនការ។
3. ការងារផែនការ

   ធ្វើរបាយការណ៍ប្រខែកក្កដា ឆ្នាំ២០១៨ ចុះប្រមូលទិន្នន័យ អណ្តូងគ្រប់ប្រភេទ ផ្លូវជនបទ និងបង្គន់អនាម័យ។
4. ការងារអធិការកិច្ច និងសវនកម្ម ៖ (គ្មានសកម្មភាព)
5. កិច្ចប្រជុំផ្សេងៗ និងទំនាក់ទំនងសាធារណៈ
   - ប្រជុំរបស់ថ្នាក់ដឹកនាំមន្ទីរប្រចាំខែ
   - ប្រជុំមន្ត្រីថ្នាក់ការិយាល័យប្រចាំខែ
   - លោកលោកស្រីប្រធាន អនុប្រធានមន្ទីរចូលរួមប្រជុំនៅសាលាខេត្ត និងលេខាធិការដ្ឋានក្រុមប្រឹក្សាជារៀងរាល់ខែ
   - ចូលរួមប្រជុំតាមការអញ្ជើញរបស់ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត។

## III. សកម្មភាពតាមវិស័យ

1. ការងារផ្លូវជនបទ

   \+ ការងារជួសជុល

- បានជួសជុល និងថែទាំខួបចំនួន ០៣ខ្សែ ប្រវែង ១៧.៦០០ម ក្រាលល្បាយថ្មភ្នំស្ថិតស្រុកកោះអណ្តែត បាទី និងត្រាំកក់ សំរេចបាន ១០០%
- បានជួសជុលផ្លូវ និងថែទាំប្រចាំចំនួន ០៥ខ្សែ ប្រវែង ៥០.៤០០ម ក្រាលល្បាយថ្មភ្នំស្ថិតស្រុកកោះអណ្តែត គីរីវង់ ទ្រាំង និងស្រុកសំរោង សំរេចបាន ៩៥%
- បានជួសជុល និងកែលម្អផ្លូវជនបទទៅជាកៅស៊ូ ចំនួន ០១ខ្សែ មានប្រវែងសរុប ១.៩០០ម ស្ថិតឃុំព្រៃរំដេងស្រុកគីរីវង់ សំរេចបាន ១០០%។

+ **ការងារស្រង់ទិន្នន័យ**
  - បានចុះស្រង់ទិន្នន័យផ្លូវ ចំនួន ០៣ខ្សែ ប្រវែងសរុប ៥,២០០ម ស្ថិតក្នុងសស្រុកត្រាំកក់។

+ **គម្រោងសាច់ប្រាក់ពលកម្ម**
  - ជួសជុលផ្លូវក្រាលគ្រួសក្រហម សរុប ១២.០៧០ម សំរេចបាន ៥០% ស្ថិតនៅស្រុកត្រាំកក់។

2. **ការងារផ្គត់ផ្គង់ទឹកជនបទ ៖ (គ្មានសកម្មភាព)**
3. **ការងារសុខភាពជនបទ**
   - បំផុសពលរដ្ឋសាងសង់បង្គន់អនាម័យ។
4. **ការងារបណ្តុះបណ្តាល**

បានធ្វើការផ្សព្វផ្សាយវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទាំងនៅក្នុងមជ្ឈមណ្ឌល និងក្រៅមជ្ឈមណ្ឌល បានចំនួន ៣៦វគ្គ មានសិក្ខាកាមចូលរួម ៧៤០នាក់ **ស្ថិតនៅសំរោង ឃុំបឹងត្រាញ់ខាងជើង ០៩ភូមិ ឃុំជើងគួន ១១ភូមិ** រួមមាន៖

| | | |
|---|---|---|
| - វគ្គបណ្តុះបណ្តាលចិញ្ចឹមមាន់ | ចំនួន ១៤ វគ្គ | សិស្សសរុប ២៨០ នាក់ |
| - វគ្គបណ្តុះបណ្តាលចិញ្ចឹមជ្រូក | ចំនួន ០៨ វគ្គ | សិស្សសរុប ១៦០ នាក់ |
| - វគ្គបណ្តុះបណ្តាលបណ្តុះផ្សិត | ចំនួន ០៥ វគ្គ | សិស្សសរុប ១០០ នាក់ |
| - វគ្គបណ្តុះបណ្តាលដំណាំគ្រួសារ | ចំនួន ០៦ វគ្គ | សិស្សសរុប ១២០ នាក់ |
| - វគ្គបណ្តុះបណ្តាលធ្វើជីកំប៉ុស៍ | ចំនួន ០១ វគ្គ | សិស្សសរុប ២០ នាក់ |
| - វគ្គបណ្តុះបណ្តាលភាសាអង់គ្លេស | ចំនួន ០២ វគ្គ | សិស្សសរុប ៦០ នាក់ |

**សរុប ស្មើនិង ៣៦វគ្គ សិស្ស ៧៤០នាក់**

5. **ការងារអភិវឌ្ឍន៍សហគមន៍**

ចុះពង្រឹង គ.អ.ភ សមរេចបាន២០ភូមិ មានអ្នកចូលរួមសរុប ៨៥នាក់ ស្រី ១៥ នាក់។ ស្ថិតស្រុកទ្រាំង និគីរីវង់។

**គម្រោងអភិវឌ្ឍន៍ជនបទដោយប្រើប្រាស់វិធីសាស្ត្រចលនាភូមិថ្មី**

- ធ្វើរបងស្រះ ១៨៤ម - ធ្វើសួនកុមារ ២០០ម៉ែត្រការ៉េ
- បង្គន់សាធារណៈ ៥ខ្នង - ផ្តល់មេក្រូ ១ឈុត
- សាងសង់ឃ្លាំងដាក់ជី ៤ខ្នង - ផ្តល់សំភារការិយាល័យ ២ឈុត
- ធ្វើរបងស្នាក់ការភូមិ ១១៨ម - ស្តារប្រឡាយ ៣០០ម
- ធ្វើតូបលក់អង្ករ ១ខ្នង

ស្ថិតក្នុងពីរ ស្រុក បាទីឃុំក្រាំងធ្នង់ និងស្រុកព្រៃកប្បាស ឃុំចំប៉ា។

6. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

+ អង្គភាពអនុវត្តគំរោងឥណទានខេត្ត ខែសីហា ឆ្នាំ ២០១៨

អង្គភាពជាអ្នកសម្របសម្រួល និងអនុវត្តកម្មវិធីទាំងឡាយ ឲ្យប្រជាពលរដ្ឋមានលទ្ធភាព បង្កើនថ្ងៃពលកម្មមានប្រាក់ចំណូលបន្ថែម ដើម្បីបង្កើនជីវភាពរស់នៅកាន់តែប្រសើរឡើង ក្នុងនោះមានប្រជាពលរដ្ឋចំនួន ៦៦ក្រុម ១៣៧ភូមិ ៦ឃុំ ២ស្រុក ដែលមានទឹកប្រាក់សរុបចំនួន ១៦៥,៥៩៥,២០០៛។

7. ការងារយេនឌ័រ ៖ (គ្មានសកម្មភាព)

8. សកម្មភាពនៅសហគមន៍

## IV. បញ្ហាប្រឈម និងដំណោះស្រាយ

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើ/ដំណោះស្រាយ |
|---|---|---|
| ១ | -ផ្លូវក្រឡុក ស្ពាន លូ បាក់ស្លាប<br>-ឡានដឹកលើសទំងន់ធ្វើផ្លូវឆាប់ខូច | -មន្ទីរបានធ្វើផែនការ ជួសជុល ថែទាំខួប ថែទាំប្រចាំ<br>-អាជ្ញាធរមូលដ្ឋានជួយសហការណ៍ |
| ២ | ប្រជាពលរដ្ឋជួបបញ្ហាកង្វះអនាម័យ | មន្ទីរបានសហការជាមួយអង្គការ នានា៖<br>- អង្គការទស្សនៈពិភពលោកបាន ចុះធ្វើការផ្សព្វផ្សាយអប់រំអនាម័យដល់ប្រជាពលរដ្ឋ និងជំរុញអោយសាងសង់បង្គន់អនាម័យ |
| ៣ | ប្រជាពលរដ្ឋបន្ទោបង់ពាសវាលពាសកាលប្រើប្រាស់បង្គន់មិនបានគ្រប់គ្រួសារទូទាំងខេត្ត | មន្ទីរបានសហការណ៍ជាមួយអង្គការ នានា ៖<br>- អង្គការទស្សនៈពិភពលោកបាន ចុះធ្វើការផ្សព្វផ្សាយ និងជម្រុញដល់មន្ត្រីរាជការ និងប្រជាពលរដ្ឋឲ្យសាងសង់បង្គន់អនាម័យ និងប្រើបង្គន់អនាម័យ |
| ៤ | ប្រជាពលរដ្ឋមួយចំនួនមានការខ្វះខាតទឹកស្អាតសម្រាប់បរិភោគ និងប្រើប្រាស់ប្រចាំថ្ងៃ | មន្ទីរបានលើកផែនការទៅក្រសួងដើម្បីស្នើសុំកញ្ចប់ថវិកាសម្រាប់ធ្វើការជួសជុលអណ្តូងគ្រប់ប្រភេទ ជូនប្រជាពលរដ្ឋ មានទឹកស្អាតបរិភោគ និងប្រើប្រាស់តាមគ្រួសារនីមួយៗ។ |

## V. ទិសដៅអនុវត្តខែបន្ទាប់

| ល.រ | សកម្មភាពអាទិភាព | សប្តាហ៍ | | | |
|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ |
| ១ | ជួសជុល និងថែទាំផ្លូវជនបទ មានខួប និងប្រចាំ | ✓ | ✓ | ✓ | ✓ |
| ២ | បញ្ជូនមន្ត្រីចុះពង្រឹងគណៈកម្មាធិការអណ្តូងស្នប់ លូ | ✓ | ✓ | ✓ | ✓ |
| ៣ | បញ្ជូនមន្ត្រីចុះពង្រឹងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ ) | ✓ | ✓ | ✓ | ✓ |
| ៤ | បន្តសហការជាមួយអង្គការដៃគូរអភិវឌ្ឍន៍នានា ទូទាំងខេត្ត | ✓ | ✓ | ✓ | ✓ |

## VI. **សេចក្តីសន្និដ្ឋាន**

អនុវត្តតាមគោលនយោបាយ យុទ្ធសាស្រ្តចតុកោណ របស់រាជរដ្ឋាភិបាលគោលការណ៍របស់ ក្រសួងអភិវឌ្ឍន៍ជនបទការបង្កលក្ខណៈងាយស្រួលរបស់អាជ្ញាធរខេត្ត និង ខិតខំប្រឹងប្រែងអនុវត្តរបស់ថ្នាក់ដឹកនាំមន្ទីរមន្ត្រីរាជការក្រោមឱវាទធ្វើឲ្យការងារអភិវឌ្ឍន៍ជនបទ ខេត្តតាកែវមានការរីកចម្រើនក្នុងខែបន្ទាប់ ឆ្នាំ២០១៨ នេះគួរជាទីមោទនភាពក្រៃលែង។ ការរីកចម្រើននេះ គឺពិតជាការចូលរួមចំណែក កាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋក្នុងខេត្តតាកែវ។

ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត